# បណ្តាញទូរសព្ទជំនួយការកង្វល់បន្ទាន់សម្រាប់កុមារ

ប្រសិនបើកូនរបស់អ្នកស្នាក់ព្យាបាលនៅក្នុងមន្ទីរពេទ្យ ហើយអ្នកព្រួយបារម្ភថាកូនអ្នកកាន់តែធ្ងន់ធ្ងរ បណ្តាញទូរសព្ទជំនួយការកង្វល់បន្ទាន់សម្រាប់កុមារអាចជួយបាន។

បណ្តាញទូរសព្ទនេះផ្តល់នូវការវាយតម្លៃឯករាជ្យអំពីការថែទាំកូនរបស់អ្នក និងធ្វើការជាមួយមន្ទីរពេទ្យដើម្បីដោះស្រាយកង្វល់របស់អ្នក។

វាឥតមានគិតថ្លៃ ងាយស្រួលប្រើ និងដំណើរការ 24/7 តាមរយៈទូរសព្ទ ឬការហៅជាវីដេអូ។

**13 82 45**

**មានផ្តល់ជូន 24/7**

## ជំហានទី 1៖ សុំជំនួយពីគិលានុបដ្ឋាក ឬវេជ្ជបណ្ឌិតរបស់អ្នក។ ពួកគេនៅទីនោះដើម្បីជួយអ្នក។

និយាយជាមួយគិលានុបដ្ឋាក ឬវេជ្ជបណ្ឌិតរបស់អ្នក៖

- ប្រសិនបើអ្នកព្រួយបារម្ភថាកូនរបស់អ្នកកាន់តែធ្ងន់ធ្ងរ
- នៅពេលកូនរបស់អ្នកមានរោគសញ្ញាថ្មីនានា
- នៅពេលអ្នកមានការព្រួយបារម្ភអំពីការថែទាំកូនរបស់អ្នក។

មន្ទីរពេទ្យទាំងអស់មានរបៀបមួយដើម្បីជួយអ្នក ប្រសិនបើអ្នកព្រួយបារម្ភថាកូនរបស់អ្នកកាន់តែធ្ងន់ធ្ងរ។

យើងចង់ឱ្យអ្នកមានការពាក់ព័ន្ធនឹងការថែទាំកូនរបស់អ្នក។ អ្នកស្គាល់កូនរបស់អ្នកច្បាស់ជាងគេ។

## ជំហានទី 2៖ ប្រសិនបើអ្នកនៅតែមានអារម្មណ៍ខ្វល់ខ្វាយ សូមរក្សានៅមន្ទីរពេទ្យ ហើយហៅទូរសព្ទលេខ 13 82 45។

បណ្តាញទូរសព្ទជំនួយការកង្វល់បន្ទាន់សម្រាប់កុមារ នឹងស្តាប់អំពីកង្វល់របស់អ្នក ហើយវាយតម្លៃអំពីតម្រូវការរបស់កូនអ្នក។ ពួកគេនឹងបង្កើតផែនការមួយជាមួយអ្នក និងរក្សាទំនាក់ទំនងជាមួយអ្នករហូតដល់អ្នកមានអារម្មណ៍សុខស្រួលជាមួយនឹងការថែទាំកូនរបស់អ្នក។

នៅពេលអ្នកហៅទូរសព្ទ អ្នកនឹងត្រូវការផ្តល់៖

- ឈ្មោះរបស់អ្នក និងអ្នកត្រូវជាអ្វីជាមួយកុមារនោះ
- ឈ្មោះ និងថ្ងៃខែឆ្នាំកំណើតរបស់កុមារ
- ព័ត៌មានលម្អិតអំពីទីតាំងរបស់អ្នកនៅមន្ទីរពេទ្យ
- លេខទូរសព្ទទំនាក់ទំនងរបស់អ្នក។

### ពេលណាដែលមិនត្រូវប្រើបណ្តាញទូរសព្ទជំនួយការកង្វល់បន្ទាន់សម្រាប់កុមារ

វាមិនមានសម្រាប់ពេលអ្នកនៅផ្ទះ ឬប្រសិនបើកូនរបស់អ្នកមានអាយុលើសពី 18 ឆ្នាំ។

វាមិនមានសម្រាប់កុមារដែលហេតុផលចម្បងនៃការស្នាក់នៅក្នុងមន្ទីរពេទ្យ គឺទាក់ទងនឹងសុខភាពផ្លូវចិត្តរបស់ពួកគេ។

វាមិនមែនជាបណ្តាញទូរសព្ទសម្រាប់បណ្តឹងតវ៉ាទេ។ ប្រសិនបើអ្នកមានបណ្តឹងតវ៉ា សូមនិយាយជាមួយបុគ្គលិកមន្ទីរពេទ្យ។

**បណ្តាញទូរសព្ទជំនួយការកង្វល់បន្ទាន់សម្រាប់កុមារ គឺជាគំនិតផ្តួចផ្តើមអំពីការថែទាំកុមារដែលកាន់តែមានសុវត្ថិភាព**

ដើម្បីទទួលបានឯកសារនេះក្នុងទម្រង់ផ្សេងទៀត សូមផ្ញើអ៊ីមែលទៅកាន់ក្រសួងសុខាភិបាលតាមរយៈ <emergencycarereform@health.vic.gov.au>

អនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋាភិបាលរដ្ឋវិកថូរៀ 1 Treasury Place ទីក្រុងមែលប៊ន។
© រដ្ឋវិកថូរៀ ប្រទេសអូស្ត្រាលី ក្រសួងសុខាភិបាល ខែមេសា ឆ្នាំ 2026។ (2510349)

**Khmer | ភាសាខ្មែរ**